## ចាប់ពីខែមករា ឆ្នាំ២០២៣តទៅ

# ជម្រាបជូន អ្នកប្រកាសស្នើសុំបន្ធូរបន្ថយពន្ធលើបន្ទុកចិញ្ចឹមអំពីសាច់ញាតិដែលមិនស្នាក់នៅក្នុងប្រទេសជប៉ុន

ខែតុលា ឆ្នាំ២០២២

អគ្គនាយកដ្ឋានពន្ធដារជាតិ

ចាប់ពីថ្ងៃទី១ ខែមករា ឆ្នាំ២០២៣នេះតទៅ អ្នកដែលជាប់ភារកិច្ចត្រូវបង់ពន្ធកាត់ទុក និង ការកែតម្រូវចុងឆ្នាំ ក្នុងករណីអ្នកមានបន្ទុកចិញ្ចឹមសាច់ញាតិ ( បន្ទុកចិញ្ចឹមសាច់ញាតិ បន្ទុកចិញ្ចឹមប្ដីឬប្រពន្ធ បន្ទុកចិញ្ចឹមប្ដីឬប្រពន្ធជាពិសេស បន្ទុកចិញ្ចឹមអ្នកពិការភាព ជាដើម) ចាំបាច់ដាក់បង្ហាញ ឬ ដាក់ស្នើទៅក្រុមហ៊ុនសហគ្រាសដែលកំពុងបម្រើការងារនូវឯកសារដែលទាក់ទងនឹងសាច់ញាតិ 「ឯកសារទាក់ទងនឹងសាច់ញាតិ」「ឯកសារទាក់ទងនឹងទិដ្ឋាការសិស្ស」「ឯកសារទាក់ទងនឹងការផ្ទេរប្រាក់」ឬ「ឯកសារផ្ទេរប្រាក់៣៨ម៉ឺនយ៉េន」ដូចមានលម្អិតខាងក្រោម។

≪ឯកសារបញ្ជាក់ទាក់ទងនឹងបន្ទុកចិញ្ចឹមសាច់ញាតិ≫

| **ការបែងចែកតាមអាយុសាច់ញាតិដែលមិនស្នាក់នៅប្រទេសជប៉ុន** | | **ឯកសារចាំបាច់ពេលដាក់ប្រកាសក្នុងបន្ទុកចិញ្ចឹមសាច់ញាតិ** | **ឯកសារចាំបាច់ពេលកែតម្រូវចុងឆ្នាំ** |
|---|---|---|---|
| អាយុចាប់ពី១៦ឆ្នាំឡើងដល់អាយុក្រោម៣០ឆ្នាំ ឬ អាយុចាប់ពី៧០ឆ្នាំឡើង | | 「ឯកសារទាក់ទងនឹងសាច់ញាតិ」 | 「ឯកសារទាក់ទងនឹងការផ្ទេរប្រាក់」 |
| អាយុចាប់ពី៣០ឆ្នាំឡើងដល់អាយុក្រោម៧០ឆ្នាំ | ① អ្នកមិនមានអាសយដ្ឋាននិងមិនស្នាក់នៅក្នុងប្រទេសរយៈពេលយូរយោងលើហេតុផលសិក្សាក្រៅប្រទេស | 「ឯកសារទាក់ទងនឹងសាច់ញាតិ」និង「ឯកសារទាក់ទងនឹងទិដ្ឋាការសិស្ស」 | 「ឯកសារទាក់ទងនឹងការផ្ទេរប្រាក់」 |
| | ② អ្នកពិការភាព | 「ឯកសារទាក់ទងនឹងសាច់ញាតិ」 | 「ឯកសារទាក់ទងនឹងការផ្ទេរប្រាក់」 |
| | ③ បុគ្គលដែលទទួលប្រាក់ពីអ្នកលើសពី៣៨ម៉ឺនយ៉េនសម្រាប់ចំណាយក្នុងការរស់នៅនិងការអប់រំក្នុងរយៈពេល១ឆ្នាំ | 「ឯកសារទាក់ទងនឹងសាច់ញាតិ」 | 「ឯកសារផ្ទេរប្រាក់៣៨ម៉ឺនយ៉េន」 |
| | (ក្រៅពី①~③ ខាងលើ) | (ក្រៅលក្ខខណ្ឌជាប់បន្ទុកចិញ្ចឹមសាច់ញាតិ) | |

≪ឯកសារបញ្ជាក់ទាក់ទងនឹងបន្ទុកចិញ្ចឹមប្ដីឬប្រពន្ធ បន្ទុកចិញ្ចឹមប្ដីឬប្រពន្ធជាពិសេស ឬ បន្ទុកចិញ្ចឹមអ្នកពិការភាព≫

| **ការដាក់ស្នើក្នុងបន្ទុកចិញ្ចឹម** | **ឯកសារចាំបាច់ពេលដាក់ប្រកាសក្នុងបន្ទុកចិញ្ចឹមសាច់ញាតិ** | **ឯកសារចាំបាច់ពេលកែតម្រូវចុងឆ្នាំ** |
|---|---|---|
| បន្ទុកចិញ្ចឹមប្ដីឬប្រពន្ធ បន្ទុកចិញ្ចឹមប្ដីឬប្រពន្ធជាពិសេស | 「ឯកសារទាក់ទងនឹងសាច់ញាតិ」<br>※អាចដាក់ក្នុងបន្ទុកបានចំពោះតែប្ដីឬប្រពន្ធត្រូវតាមគោលដៅនៃការកាត់ទុក | 「ឯកសារទាក់ទងនឹងសាច់ញាតិ」និង「ឯកសារទាក់ទងនឹងការផ្ទេរប្រាក់」* |
| បន្ទុកចិញ្ចឹមអ្នកពិការភាព | 「ឯកសារទាក់ទងនឹងសាច់ញាតិ」 | 「ឯកសារទាក់ទងនឹងការផ្ទេរប្រាក់」 |

*(ចំណាំ)នៅពេលដាក់ពាក្យស្នើសុំទទួលបន្ទុកចិញ្ចឹមប្ដីឬប្រពន្ធពេលកែតម្រូវពន្ធចុងឆ្នាំ ចាំបាច់ដាក់បង្ហាញឬដាក់ស្នើឯកសារបញ្ជាក់ទាំងអស់នេះ។ ប៉ុន្តែពេលដាក់ស្នើទម្រង់ប្រកាសក្នុងបន្ទុកចិញ្ចឹម អំពីប្ដីឬប្រពន្ធដែលមិនស្នាក់នៅប្រទេសជប៉ុន ករណីបានដាក់ឬបង្ហាញនូវ「ឯកសារទាក់ទងនឹងសាច់ញាតិ」ទៅកាន់ក្រុមហ៊ុនសហគ្រាសដែលកំពុងបម្រើការងាររួចហើយ មិនចាំបាច់ដាក់ឬបង្ហាញ「ឯកសារទាក់ទងនឹងសាច់ញាតិ」ទៅកាន់ក្រុមហ៊ុនទេ នៅពេលដាក់ទម្រង់ប្រកាសក្នុងបន្ទុកចិញ្ចឹមប្ដីឬប្រពន្ធ។

ករណីដាក់ទទួលបន្ទុកចិញ្ចឹមសាច់ញាតិដែលសាច់ញាតិមិនស្នាក់នៅក្នុងប្រទេសជប៉ុន នៅពេលប្រកាសពន្ធចុងក្រោយ ត្រូវភ្ជាប់ទម្រង់ប្រកាសពន្ធចុងឆ្នាំជាមួយ「ឯកសារទាក់ទងនឹងសាច់ញាតិ」「ឯកសារទាក់ទងនឹងទិដ្ឋាការសិស្ស」「ឯកសារទាក់ទងនឹងការផ្ទេរប្រាក់」ឬ「ឯកសារផ្ទេរប្រាក់៣៨ម៉ឺនយ៉េន」ចាំបាច់បង្ហាញពេលដាក់ស្នើប្រកាសពន្ធចុងក្រោយ។ ប៉ុន្តែប្រសិនធ្លាប់បានដាក់ឬបង្ហាញទៅក្រុមហ៊ុនសហគ្រាសដែលកំពុងបម្រើការងាររួចហើយ នោះមិនចាំបាច់ដាក់ឯកសារទាំងនេះម្ដងទៀតទេពេលដាក់ទទួលបន្ទុកចិញ្ចឹមនៅក្នុងការកែតម្រូវចុងឆ្នាំ។

## ◎「ឯកសារទាក់ទងនឹងសាច់ញាតិ」គឺជាអ្វី?

អ្វីទៅជា「ឯកសារទាក់ទងនឹងសាច់ញាតិ」ឯកសារក្នុងចំណោមលេខ១ឬលេខ២បន្ទាប់នេះ(ត្រូវការបកប្រែជាភាសាជប៉ុន)ជាបន្ទាល់ថាសាច់ញាតិ ដែលមិនស្នាក់នៅប្រទេសជប៉ុន ជាសាច់ញាតិរបស់អ្នក។

១. ឯកសារចេញដោយរដ្ឋាភិបាលជប៉ុនឬអាជ្ញាធក្នុងស្រុក ដូចជាច្បាប់ចម្លងភ្ជាប់ជាមួយបញ្ជីគ្រួសារជាដើមនិងច្បាប់ចម្លងលិខិតឆ្លងដែនរបស់សាច់ញាតិដែលមិនស្នាក់នៅប្រទេសជប៉ុន។

២. ឯកសារចេញដោយរដ្ឋាភិបាលបរទេសឬអាជ្ញាធរក្នុងស្រុកបរទេស(ឯកសារដែលកំណត់ពីការកត់ត្រាឈ្មោះសាច់ញាតិ ថ្ងៃខែឆ្នាំកំណើត អាសយដ្ឋាន ឬ ការកត់ត្រាចូលស្នាក់នៅ)។

*(ចំណាំ)

១.ឯកសារដែលចេញដោយរដ្ឋាភិបាលបរទេសឬអាជ្ញាធរក្នុងស្រុកបរទេស ដូចជា សៀវភៅគ្រួសារ សំបុត្រកំណើត សំបុត្រអាពាហ៍ពិពាហ៍ជាដើម ជាឯកសារដែលអាចប្រើប្រាស់បាន។

២.ករណីឯកសារតែ១ដែលមិនមាន ឈ្មោះ ថ្ងៃខែឆ្នាំកំណើត និង អាសយដ្ឋានរបស់សាច់ញាតិ ចុះក្នុងបញ្ជីទេ និងករណីឯកសារមិនអាចប្រើបញ្ជាក់ថាជាសាច់ញាតិដែលមិនស្នាក់នៅប្រទេសជប៉ុនទេ ចាំបាច់ត្រូវប្រើឯកសារផ្សេងទៀតភ្ជាប់មកជាមួយដើម្បីបញ្ជាក់។

៣.ឯកសារទាក់ទងនឹងសាច់ញាតិគឺ ចាំបាច់ដាក់ឬបង្ហាញច្បាប់ដើមនៃលិខិតឆ្លងដែនរបស់សាច់ញាតិដែលរស់នៅក្រៅប្រទេស។

៤.ករណីសាច់ញាតិដែលមិនស្នាក់នៅប្រទេសជប៉ុនមានអាយុក្រោម១៦ឆ្នាំមិនអាចដាក់ក្នុងបន្ទុកក៏ដោយ ប៉ុន្តែប្រសិនបើដាក់ជាបន្ទុកចិញ្ចឹមអ្នកពិការភាព ចាំបាច់ត្រូវបង្ហាញឬដាក់ស្នើឯកសារទាក់ទងនឹងសាច់ញាតិ និង ឯកសារទាក់ទងនឹងការផ្ទេរប្រាក់។

៥.សាច់ញាតិដែលជាប់ក្នុងគោលដៅទទួលបន្ទុកចិញ្ចឹមគឺ ប្ដីឬប្រពន្ធ និង សាច់ញាតិដែលជាប់សាច់សាលោហិត៦ជំនាន់ សាច់ថ្លៃ៣ជំនាន់។

## ◎「ឯកសារទាក់ទងនឹងទិដ្ឋាការសិស្ស」គឺជាអ្វី?

អ្វីទៅជា「ឯកសារទាក់ទងនឹងទិដ្ឋាការសិស្ស」ឯកសារចេញដោយរដ្ឋាភិបាលបរទេសឬអាជ្ញាធរក្នុងស្រុកបរទេស ឯកសារណាមួយក្នុងចំណោមលេខ១ឬលេខ២បន្ទាប់នេះ(ត្រូវការបកប្រែជាភាសាជប៉ុន)ជាបន្ទាល់ថាយោងលើការបន្តការសិក្សានៅក្រៅប្រទេសសាច់ញាតិដែលមិនស្នាក់នៅប្រទេសជប៉ុនរយៈពេលយូរហើយមិនមានអាសយដ្ឋាននៅក្នុងស្រុក ។

១.ច្បាប់ចម្លងទិដ្ឋាការនៅបរទេស

២.ច្បាប់ចម្លងប័ណ្ណស្នាក់នៅបរទេស

*(ចំណាំ) សម្រាប់ជនជាតិជប៉ុនដែលចេញទៅរស់នៅក្រៅប្រទេស។

## ◎「ឯកសារទាក់ទងនឹងការផ្ទេរប្រាក់」គឺជាអ្វី?

អ្វីទៅជា「ឯកសារទាក់ទងនឹងការផ្ទេរប្រាក់」ឯកសារបន្ទាប់នេះត្រូវការច្បាប់បកប្រែជាភាសាជប៉ុន នៅក្នុងឆ្នាំនេះអ្នកបានចំណាយលើថ្លៃសិក្សា ការចំណាយក្នុងការរស់នៅរបស់សាច់ញាតិម្នាក់ៗដែលមិនស្នាក់នៅក្នុងប្រទេសជប៉ុន។

១.ឯកសារដែលចេញដោយគ្រឹះស្ថានហិរញ្ញវត្ថុ ជាឯកសារដែលបញ្ជាក់ឃើញច្បាស់ថាអ្នកបានចំណាយលើសាច់ញាតិដែលមិនស្នាក់នៅក្នុងប្រទេសជប៉ុនយោងតាមប្រតិបត្តិការប្ដូរប្រាក់ចេញដោយគ្រឹះស្ថានហិរញ្ញវត្ថុនោះ។

២.ឯកសារដែលបានចេញដោយក្រុមហ៊ុនឥណទានឬច្បាប់ចម្លងនៃឯកសារនោះ ដោយសាច់ញាតិអ្នកដែលមិនស្នាក់នៅក្នុងប្រទេសជប៉ុនប្រើប្រាស់ប័ណ្ណឥណទាននោះដើម្បីទូទាត់លើការជាវទំនិញ និង ការទទួលសេវាកម្មផ្សេងៗ ហើយការចំណាយលើប័ណ្ណឥណទានជាបន្ទុករបស់អ្នក ដូច្នេះអ្នកអាចប្រើបង្កាន់ដៃនោះជាឯកសារបញ្ជាក់។

*(ចំណាំ)

១.ឯកសារទាក់ទងនឹងការផ្ទេរប្រាក់មានជាឧទាហរណ៍ដូចនឹងឯកសារបន្ទាប់នេះ។

ប៉ុន្តែករណីពឹងពាក់អ្នកស្គាល់គ្នាជួយផ្តល់ជាសាច់ប្រាក់ទៅសាច់ញាតិដែលមិនស្នាក់នៅប្រទេសជប៉ុនសម្រាប់ចំណាយក្នុងការរស់នៅ ដូច្នេះនឹងមិនមានឯកសារទាក់ទងនឹងការផ្ទេរប្រាក់ទេ។ សូមប្រុងប្រយ័ត្នដោយសារមិនអាចដាក់ចូលជាបន្ទុកចិញ្ចឹមបានទេ។

① ច្បាប់ចម្លងនៃឯកសារផ្ទេរប្រាក់ក្រៅប្រទេស

※ត្រូវការចាំបាច់នូវច្បាប់ចម្លងឯកសារស្នើសុំផ្ទេរប្រាក់ក្រៅប្រទេសដែលបានផ្ទេរក្នុងឆ្នាំនោះ។

② របាយការណ៍ប្រើប្រាស់ប័ណ្ណឥណទាន

※១. ដែលហៅថារបាយការណ៍ប្រើប្រាស់ប័ណ្ណឥណទាន គឺអ្នកបានភ្ជាប់កិច្ចសន្យាជាមួយក្រុមហ៊ុនចេញប័ណ្ណឥណទាន ហើយសាច់ញាតិអ្នកដែលមិនស្នាក់នៅប្រទេសជប៉ុនប្រើប្រាស់ប័ណ្ណឥណទាននោះ សម្រាប់ការចំណាយលើប័ណ្ណនោះជាបន្ទុករបស់អ្នក។ ករណីនេះរបាយការណ៍នោះមានឈ្មោះសាច់ញាតិអ្នក ដូច្នេះអាចប្រើប្រាស់ឯកសារនោះបានដូចគ្នានឹង ឯកសារទាក់ទងនឹងការផ្ទេរប្រាក់ ផងដែរ។

២. របាយការណ៍ប្រើប្រាស់ប័ណ្ណឥណទាន អាចប្រើជាឯកសារទាក់ទងនឹងការផ្ទេរប្រាក់បានដោយយោងតាមកាលបរិច្ឆេទប្រើប្រាស់ប័ណ្ណឥណទាន។

២. ករណីអ្នកដាក់សាច់ញាតិមិនស្នាក់នៅប្រទេសជប៉ុន ក្នុងបន្ទុកចិញ្ចឹមច្រើននាក់ តម្រូវឱ្យផ្ទេរប្រាក់ទៅកាន់សាច់ញាតិម្នាក់ៗ។ ឧទាហរណ៍ ករណីដាក់បន្ទុកចិញ្ចឹមសាច់ញាតិមិនស្នាក់នៅប្រទេសជប៉ុនជាប្តីឬប្រពន្ធ និង កូន នៅពេលផ្ទេរប្រាក់សម្រាប់ចំណាយក្នុងការរស់នៅសរុបទៅប្តីឬប្រពន្ធ ដូច្នេះឯកសារទាក់ទងនឹងការផ្ទេរប្រាក់នោះគឺអាចប្រើសម្រាប់តែប្តីឬប្រពន្ធប៉ុណ្ណោះ ហើយឯកសារនោះមិនអាចប្រើជាឯកសារទាក់ទងនឹងការផ្ទេរប្រាក់របស់កូនទេ។

៣. អំពីឯកសារទាក់ទងនឹងការផ្ទេរប្រាក់ សម្រាប់អ្នកដាក់បន្ទុកចិញ្ចឹមក្នុងឆ្នាំនោះ តម្រូវឱ្យបង្ហាញ ឬ ដាក់ឯកសារផ្ទេរប្រាក់ទាំងអស់ជាចាំបាច់។

ប៉ុន្តែករណីផ្ទេរប្រាក់ទៅសាច់ញាតិដដែលមិនស្នាក់នៅប្រទេសជប៉ុនក្នុង១ឆ្នាំ៣ដងហើយរបាយការណ៍បានបង្ហាញពីចំនួនជាក់លាក់មួយ ដូច្នេះអាចដាក់ ឬ បង្ហាញឯកសារទាក់ទងនឹងការផ្ទេរប្រាក់លើកដំបូង និង ចុងក្រោយនៃឆ្នាំ ដែលបានផ្ញើទៅសាច់ញាតិដែលមិនរស់នៅក្នុងប្រទេសជប៉ុន ហើយការដាក់ស្នើ ឬ បង្ហាញទាក់ទងនឹងឯកសារផ្ទេរប្រាក់ផ្សេងទៀត អាចកាត់ចេញបាន។ លើសពីនេះទៀត អ្នកត្រូវតែរក្សាទុកឯកសារផ្ទេរប្រាក់សង្ខេបដែលបានដាក់ស្នើ ឬ បង្ហាញនោះ។

៤. សម្រាប់សាច់ញាតិមិនស្នាក់នៅប្រទេសជប៉ុនដែលមានអាយុក្រោម១៦ឆ្នាំមិនអាចចូលក្នុងលក្ខខណ្ឌបន្ទុកចិញ្ចឹម ប៉ុន្តែករណីដាក់បន្ទុកចិញ្ចឹមអ្នកពិការភាពចាំបាច់បង្ហាញ ឬ ដាក់ឯកសារទាក់ទងនឹងការផ្ទេរប្រាក់ និង ឯកសារទាក់ទងនឹងសាច់ញាតិ ។

## ◎「ឯកសារផ្ទេរប្រាក់៣៨ម៉ឺនយ៉េន」គឺជាអ្វី?

「ឯកសារផ្ទេរប្រាក់៣៨ម៉ឺនយ៉េន」គឺជាឯកសារបង្ហាញពីចំនួនទឹកប្រាក់សរុបចាប់ពី៣៨ម៉ឺនយ៉េនឡើង ផ្ទេរទៅសាច់ញាតិម្នាក់ៗដែលមិនស្នាក់នៅជប៉ុន។

*(ចំណាំ) អំពីឯកសារផ្ទេរប្រាក់៣៨ម៉ឺនយ៉េន ចាំបាច់បង្ហាញ ឬ ដាក់ឯកសារទាំងអស់ដែលបានធ្វើការផ្ទេរប្រាក់ក្នុងឆ្នាំនោះ សម្រាប់ទទួលបន្ទុកចិញ្ចឹម។

ប៉ុន្តែករណីផ្ទេរប្រាក់ទៅសាច់ញាតិដដែលមិនស្នាក់នៅប្រទេសជប៉ុនក្នុង១ឆ្នាំ៣ដងហើយរបាយការណ៍បានបង្ហាញពីចំនួនជាក់លាក់មួយ ដូច្នេះអាចដាក់ ឬ បង្ហាញឯកសារទាក់ទងនឹងការផ្ទេរប្រាក់លើកដំបូង និង ចុងក្រោយនៃឆ្នាំ ដែលបានផ្ញើទៅសាច់ញាតិដែលមិនរស់នៅក្នុងប្រទេសជប៉ុន ហើយការដាក់ស្នើ ឬ បង្ហាញឯកសារផ្សេងទៀត អាចកាត់ចេញបាន។

លើសពីនេះទៀត ប្រសិនបើ「ឯកសារដែលបានផ្ទេរប្រាក់ដំបូងនិងចុងក្រោយបង្អស់ក្នុងឆ្នាំនោះ」ដូចមានសំរាយខាងលើ ចំនួនផ្ទេរប្រាក់សរុបក្រោម៣៨ម៉ឺនយ៉េន បន្ថែមពីលើ「ឯកសារដែលបានផ្ទេរប្រាក់ដំបូងនិងចុងក្រោយបង្អស់ក្នុងឆ្នាំនោះ」ចាំបាច់ត្រូវដាក់បង្ហាញឯកសារផ្ទេរប្រាក់ទៅសាច់ញាតិមិនស្នាក់នៅប្រទេសជប៉ុន ដែលអាចបញ្ជាក់ចំនួនផ្ទេរប្រាក់ចាប់ពី៣៨ម៉ឺនយ៉េនឡើង។ (ឧ. ចំនួនទឹកប្រាក់ផ្ទេរសរុបទាក់ទងនឹង「ឯកសារដែលបានផ្ទេរប្រាក់ដំបូងនិងចុងក្រោយបង្អស់ក្នុងឆ្នាំនោះ」ករណី៣០ម៉ឺនយ៉េន តម្រូវឱ្យដាក់បន្ថែមជាចាំបាច់នូវឯកសារបង្ហាញពីចំនួនទឹកប្រាក់ផ្ទេរ ចាប់ពី៨ម៉ឺនយ៉េន (៣៨ម៉ឺនយ៉េន-៣០ម៉ឺនយ៉េន )។ លើសពីនេះទៀត អ្នកត្រូវតែរក្សាឯកសារផ្ទេរប្រាក់មិនបានបញ្ចូល៣៨ម៉ឺនយ៉េនដែលដាក់បង្ហាញនោះ។

※មានផ្សាយនៅលើគេហទំព័រអគ្គនាយកដ្ឋានពន្ធដារជាតិ សូមបញ្ជាក់លម្អិត៖

https://www.nta.go.jp/publication/pamph/pdf/0022009-107_02.pdf

※ ទម្រង់នេះបានធ្វើឡើងដោយផ្អែកលើបទប្បញ្ញត្តិពាក់ព័ន្ធនៃច្បាប់ពន្ធលើប្រាក់ចំណូលគិតមកដល់ត្រឹមថ្ងៃទី១ ខែកញ្ញា ឆ្នាំ២០២២។